**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៨២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាក្រុងស្វាយរៀង នៃខេត្តស្វាយរៀង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/0៩0៨/១0៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២00៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ 0២/នស/៩៤ ចុះថ្ងៃទី ២0 ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ 0៦/នស/៩៤ ចុះថ្ងៃទី ៣0 ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/0១៩៦/0៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/0៥0៨/0១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២00៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/0៥0៨/0១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២00៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ១៣៧ គជប.សសរ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២00៩ ស្តីពីបេក្ខជនជាប់ឆ្នោតក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សាក្រុងស្វាយរៀង នៃខេត្តស្វាយរៀង អាណត្តិទី១ ដូចមានរាយនាមខាងក្រោម :

១- លោក **ចក់ សំអុល** ជាប្រធានក្រុមប្រឹក្សាក្រុង
២- លោក **ហ៊ីង ឆុង** ជាសមាជិកក្រុមប្រឹក្សាក្រុង
៣- លោក **ពៅ សារ៉ង** ជាសមាជិកក្រុមប្រឹក្សាក្រុង
៤- លោក **ទ្រាំ សាល់** ជាសមាជិកក្រុមប្រឹក្សាក្រុង
៥- លោក **អ៊ុំ ខុន** ជាសមាជិកក្រុមប្រឹក្សាក្រុង
៦- លោកស្រី **ជុំ រំដួល** ជាសមាជិកក្រុមប្រឹក្សាក្រុង
៧- លោក **ស៊ីង សាវ៉ុន** ជាសមាជិកក្រុមប្រឹក្សាក្រុង
៨- លោក **សៅ សំអាន** ជាសមាជិកក្រុមប្រឹក្សាក្រុង
៩- លោក **សេក ឌិន** ជាសមាជិកក្រុមប្រឹក្សាក្រុង
១០- លោក **ជ័យ សាវឿត** ជាសមាជិកក្រុមប្រឹក្សាក្រុង
១១- លោក **ឯក សារុំ** ជាសមាជិកក្រុមប្រឹក្សាក្រុង
១២- លោកស្រី **ហ៊ុន លក្ខិណា** ជាសមាជិកក្រុមប្រឹក្សាក្រុង
១៣- លោក **ម៉ៅ សារម៉េត** ជាសមាជិកក្រុមប្រឹក្សាក្រុង
១៤- លោកស្រី **ពេជ វាសនា** ជាសមាជិកក្រុមប្រឹក្សាក្រុង
១៥- លោក **គង់ ដារ៉ាវីត** ជាសមាជិកក្រុមប្រឹក្សាក្រុង ។

**មាត្រា ២ :** ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់ បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ២២ និងមាត្រា២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៣ :** ក្នុងការអនុវត្តការងារ ប្រធាន និងសមាជិកក្រុមប្រឹក្សាក្រុងស្វាយរៀង នៃខេត្តស្វាយរៀង ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន ។

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**__កន្លែងទទួល :__**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*
  *(ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៥*
- *ឯកសារ កាលប្បវត្តិ*